**សុន្ទរកថារបស់ ឯកឧត្តម គូម៉ាម៉ារូ យូជិ**
**ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន**

០៥ កញ្ញា ២០១៦

**សូមគោរព លោកស្រី ណាកាតា យូស៊ីមិ នាយិកាប្រចាំប្រទេសអង្គការមូលនិធិជប៉ុនPHJ**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីរៀបចំពិធីចុះហត្ថលេខាផ្តល់ជំនួយនេះសម្រាប់ “គម្រោងពង្រឹងប្រព័ន្ធថែទាំសុខភាពបឋមមាតា និងទារកនៅខេត្តកំពង់ចាម” ដែលត្រូវបានអនុវត្តដោយអង្គការមូលនិធិជប៉ុនPHJ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន។

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីកែលម្អស្ថានភាពសុខភាពមាតា និងទារកអោយកាន់តែប្រសើរឡើង ដោយបានដាក់វិស័យសុខភាពមាតា និងទារកនេះនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រនៃវិស័យសុខាភិបាលដំណាក់កាលទី៣ផងដែរ។ យ៉ាងណាមិញ ដោយសារតែការជះឥទ្ធិពលនៃសង្គ្រាមស៊ីវិលអស់រយៈពេលជាច្រើនឆ្នាំមកនេះ ខ្ញុំបានទទួលដំណឹងថាប្រទេសកម្ពុជានៅមានបញ្ហាជាច្រើនដូចជា កង្វះខាតនូវការកែលម្អហេដ្ឋរចនាសម្ព័ន្ធផ្នែកសុខាភិបាល ជាពិសេសនៅតាមតំបន់ជនបទ និងកង្វះខាតនូវធនធានមនុស្សក្នុងវិស័យសុខាភិបាលជាដើម។

រដ្ឋាភិបាលជប៉ុន បាននឹងកំពុងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍរបស់ប្រជាជនកម្ពុជា ដោយផ្តល់ជំនួយឧបត្ថម្ភលើគម្រោងជាច្រើនរួមមាន៖ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងវិស័យសុខភាពមាតា និងទារក។ ជាពិសេស នៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកដែលត្រូវបានសាងសង់ឡើងដោយជំនួយរបស់ជប៉ុននៅក្នុងឆ្នាំ១៩៩៧ ក្នុងនោះរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមបញ្ជូនអ្នកជំនាញការមកដើម្បីជួយអភិវឌ្ឍធនធានមនុស្ស។ ថ្មីៗនេះ រដ្ឋាភិបាលជប៉ុន មិនត្រឹមតែបានសាងសង់មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកប៉ុណ្ណោះទេ ថែមទាំងបានបង្កើតទីតាំងនៅក្នុងខេត្តផ្សេងៗ ដើម្បីលើកស្ទួយស្ថានភាពសុខភាពមាតា និងទារកផងដែរ។

នៅក្នុងឆ្នាំ២០០៤ អង្គការមូលនិធិជប៉ុនPHJ បានចាប់ផ្តើមគម្រោងរបស់ខ្លួននៅក្នុងខេត្តកំពង់ធំ ហើយចាប់តាំងពីពេលនោះមក អង្គការនេះបានបន្តអនុវត្តគម្រោងមួយចំនួនដែលក្នុងនោះរួមមាន៖ ការកែលម្អស្ថានភាពសុខភាពមាតា និងទារកនៅតំបន់ជនបទ និងការផ្តល់វគ្គបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងវិស័យសុខាភិបាល។ នៅពេលដែលខេត្តកំពង់ធំ បានរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារគ្រោះទឹកជំនន់ខ្លាំងកាលពីឆ្នាំ២០១១កន្លងមកនេះ អង្គការមូលនិធិជប៉ុនPHJ ក៏បានផ្តល់នូវរបស់សង្គ្រោះបន្ទាន់ផងដែរ។ អង្គការមូលនិធិជប៉ុនPHJ បានបន្តសកម្មភាពរបស់ខ្លួនយ៉ាងសកម្មផ្នែកជំនួយអស់រយៈពេលជាច្រើនឆ្នាំមកហើយ។

នៅក្នុងឆ្នាំទី១ នៃគម្រោងរយៈពេល៣ឆ្នាំនេះ អង្គការមូលនិធិជប៉ុនPHJ បានផ្តោតជាសំខាន់លើការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងវិស័យសុខាភិបាល ហើយខ្ញុំបានទទួលដំណឹងថា ចំណេះដឹងផ្នែកសុខាភិបាល សមត្ថភាពគ្រប់គ្រង និងជំនាញផ្នែកសម្របសម្រួលរបស់ពួកគេ មានលក្ខណៈល្អប្រសើរ។

នៅក្នុងឆ្នាំទី២ នៃគម្រោងដែលទើបតែបានចុះហត្ថលេខានៅថ្ងៃនេះ រដ្ឋាភិបាលជប៉ុនបានផ្តល់ប្រមាណ ១៣ ម៉ឺនដុល្លារអាមេរិកដល់អង្គការមូលនិធិជប៉ុនPHJ ដែលសង្ឃឹមថា អង្គការមូលនិធិជប៉ុនPHJ នឹងពង្រឹងប្រព័ន្ធថែទាំសុខភាពនៅការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្ទឹងត្រង់ មិនត្រឹមតែគាំទ្រការកែលម្អមណ្ឌលសុខភាព និងការបំពាក់បរិក្ខាពេទ្យផ្សេងៗប៉ុណ្ណោះទេ ថែមទាំងផ្តល់វគ្គបណ្តុះបណ្តាលដល់ឆ្មបកម្រិតមធ្យមតាមមណ្ឌលសុខភាពនិមួយៗ និងអ្នកស្ម័គ្រចិត្តសុខាភិបាលតាមភូមិមួយចំនួន និងការពង្រឹងផ្នែកគ្រប់គ្រងនៅការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្ទឹងត្រង់នេះផងដែរ។

ជាចុងក្រោយនេះ ក្រោមគ្រោងការណ៍ជំនួយឧបត្ថម្ភសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ត្រូវបានបង្កើតឡើងសម្រាប់ផ្តល់ជំនួយដែលចាំបាច់ដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលអនុវត្តគម្រោងនានាដើម្បីជួយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ប្រជាពលរដ្ឋនៅក្នុងតំបន់គោលដៅ ព្រមទាំងពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានរួចស្រាប់មកហើយរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។ ខ្ញុំសង្ឃឹមថា ការចូលរួម និងគាំទ្រពីមន្ត្រីសុខាភិបាលទាំងអស់ អាចនឹងពង្រឹងប្រព័ន្ធថែទាំសុខភាពមាតា និងទារកដល់ប្រជាពលរដ្ឋនៅក្នុងតំបន់គោលដៅទាំងនេះផងដែរ។ ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់ និងកិច្ចសហប្រតិបត្តិការរបស់លោក-អ្នកទាំងអស់នៅក្នុងបញ្ហានេះ។

**សូមអរគុណ!**